ការប្រមូលត្រឡប់មកវិញ នូវផលិតផលកង់កង់បី Fisher-Price®
មានការប្រកាសអំពីការប្រមូលត្រឡប់មកវិញនូវផលិតផលទាំងនេះ។

ក្រុមហ៊ុន Mattel សហការជាមួយនិយ័តករសុវត្ថិភាពដែលពាក់ព័ន្ធ កំពុងធ្វើការប្រមូលត្រឡប់មកវិញនូវផលិតផលកង់កង់បីម៉ាក Fisher-Price® Trikes និង Tough Trikes ។ កង់កង់បីទាំងនេះត្រូវបានផលិតឡើងសម្រាប់កុមារដែលមានអាយុពី ២ ទៅ ៥ឆ្នាំ។ កង់ទាំងនោះមានកូនសោសិប្បនិម្មិតស្ថិតនៅប្រហែល ៣អ៊ិញ ពីមុខកៅអី និងលយចេញយ៉ាងហោចណាស់ ៥/៨ អ៊ិញខាងលើតួកង់។

**កុមារអាចបុកប៉ះ អង្គុយលើឬធ្លាក់លើកូនសោផ្លាស្ទិកសម្រាប់បញ្ឆេះដែលលយចេញ ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់។**

**ការប្រមូលផលិតផលត្រឡប់មកវិញនេះ មិនរាប់បញ្ចូលនូវកង់ Lights and Sounds, Rock, Roll’n Ride Trike; Grow-With-Me Trikes; Action Sounds Trike, Push’n Pedal Trike ឡើយ។ កង់កង់បីទាំងនេះមិនមានសោស្ថិតនៅមុខកៅអីទេ។ រាល់ផលិតផលកង់ Fisher-Price® ដែលមានសោស្ថិតនៅដៃកង់ មិនប៉ះពាល់ដល់ការប្រមូលផលិតផលត្រឡប់មកវិញទេ។**

សូមប្រើប្រាស់ការណែនាំតាមប្រព័ន្ធអ៊ីនធើណែតសម្រាប់កំណត់ថា តើផលិតផលរបស់លោកអ្នកត្រូវបានរាប់បញ្ចូលទៅក្នុងការប្រមូលផលិតផលត្រឡប់មកវិញនេះដែរឬទេ។ សូមដាក់ផលិតផលរបស់លោកអ្នកនៅជិតខ្លួន ក្នុងខណៈដែលលោកអ្នកបន្តសិក្សាអំពីបញ្ហានេះ។

**ប្រភេទផលិតផល (ម៉ូដែល) ដែលរាប់បញ្ចូលនៅក្នុងការប្រមូលផលិតផលត្រឡប់មកវិញ**
លេខម៉ូដែលស្ថិតនៅក្នុងថតក្រោមកៅអី។

| | | | |
|---|---|---|---|
| B8775 Kawasaki Tough Trike |  | B8776 Barbie™ Tough Trike |  |
| K6672 Nick Jr. Dora the Explorer Tough Trike |  | K6673 Go Diego Go!™ Tough Trike |  |
| N6021 Kawasaki Tough Trike |  | | |

ប្រសិនបើលោកអ្នកមិនមានកង់កង់បីដូចបានបង្ហាញក្នុងរូបខាងលើនោះទេ លោកអ្នក**មិន**រងការប៉ះពាល់អំពីការប្រមូលផលិតផលត្រឡប់មកវិញនេះឡើយ ហើយសូមអញ្ជើញបន្តសប្បាយរីករាយចំពោះកង់កង់បីរបស់អ្នកតទៅទៀត។

ប្រសិនបើលោកអ្នកមានកង់កង់បីណាមួយខាងលើ ឬលោកអ្នកមិនប្រាកដថាកង់កង់បីរបស់លោកអ្នកមានក្នុងចំណោមរូបភាពខាងលើ សូមពិនិត្យមើលកូនសោនៅលើផលិតផលកង់កង់បី Fisher-Price® Trikes របស់លោកអ្នក។




ប្រសិនបើកូនសោកង់កង់បីរបស់លោកអ្នកស្ថិតនៅកន្លែងណាមួយដែលមិនមែនប្រវែងប្រហែល ៣អ៊ិញ ពីមុខកៅអី និងលយចេញយ៉ាងហោចណាស់ ៥/៨អ៊ិញចេញពីតួកង់ទេនោះ លោកអ្នក**មិនរងការប៉ះពាល់**ចំពោះការប្រមូលផលិតផលត្រឡប់មកវិញនេះទេ ហើយសូមអញ្ជើញបន្តសប្បាយរីករាយកម្សាន្តជាមួយកង់កង់បីរបស់លោកអ្នកតទៅទៀត។

ប្រសិនបើកូនសោកង់កង់បីរបស់លោកអ្នកស្ថិតនៅប្រហែល ៣អ៊ិញពីមុខកៅអី និងលយចេញយ៉ាងហោចណាស់ ៥/៨អ៊ិញពីតួកង់ សូមធ្វើការពិនិត្យមើលរាងកូនសោនោះ។



ប្រសិនបើកូនសោមានរាងសំប៉ែតរាបស្មើជាអក្សរ D ដូចនៅក្នុងរូប លោកអ្នក**មិនរងការប៉ះពាល់**អំពីការប្រមូលផលិតផលត្រឡប់មកវិញទេ ហើយលោកអ្នកអាចបន្តការកម្សាន្តតទៅទៀត។



ប្រសិនបើកូនសោមានរាងមូលដូចនៅក្នុងរូបនេះ នោះអ្នកនឹង**រងការប៉ះពាល់**អំពីការប្រមូលផលិតផលត្រឡប់មកវិញនេះ។

**សូមបញ្ឈប់ការប្រើប្រាស់កង់កង់បីរបស់លោកអ្នកជាបន្ទាន់។**



ប្រសិនបើកូនសោកង់កង់បីមានរាងអក្សរ D ដូចនៅក្នុងរូប នោះលោកអ្នកនឹង**រងការប៉ះពាល់**អំពីការប្រមូលផលិតផលត្រឡប់មកវិញ។

**សូមបញ្ឈប់ការប្រើប្រាស់កង់កង់បីរបស់លោកអ្នកជាបន្ទាន់។**

សម្រាប់ការណែនាំបន្ថែម សូមទាក់ទងក្រុមហ៊ុន Mattel តាមរយៈលេខទូរស័ព្ទ (៨៩៥-២៣) ២១៧ ៦១៧ ចាប់ពីម៉ោង ៩ព្រឹក ដល់ម៉ោង ៦ល្ងាច ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ឬអញ្ជើញចូលទៅកាន់គេហទំព័ររបស់ក្រុមហ៊ុនយើងខ្ញុំ គឺ www.service.mattel.com ។

ការព្រួយបារម្ភដ៏ធំបំផុតរបស់យើងខ្ញុំ គឺតែងតែគិតគូរអំពីសុវត្ថិភាពរបស់កុមារដែលលេងប្រដាប់ប្រដាកំសាន្តរបស់យើងខ្ញុំ អាស្រ័យហេតុនេះ ទើបយើងខ្ញុំបានឆ្លើយតបយ៉ាងរហ័ស ក្នុងការព្យាយាមដើម្បីរក្សាទំនុកចិត្តពីសំណាក់ក្រុមគ្រួសារទាំងឡាយ ដែលបានអនុញ្ញាតឱ្យយើងខ្ញុំស្ថិតនៅជាផ្នែកមួយនៃការរស់នៅរបស់ពួកគេ។